# កិច្ចព្រមព្រៀងពាណិជ្ជកម្ម

## រវាង

## រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

## និង

## រដ្ឋាភិបាល នៃ សាធារណរដ្ឋឥណ្ឌា

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃសាធារណរដ្ឋឥណ្ឌា ខាងក្រោមនេះហៅកាត់ថា " ភាគីចុះហត្ថលេខា " ។

ក្នុងគោលបំណងពង្រីក និង ពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និង សេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នា និង មានផលប្រយោជន៍ទៅវិញទៅមក ។

បានព្រមព្រៀងគ្នាដូចតទៅ:

**<u>មាត្រា ១</u>**

អនុលោមតាមច្បាប់ បទបញ្ញត្តិ និង បែបបទជាធរមានរបស់ប្រទេសទាំងពីរ ភាគីចុះហត្ថលេខាត្រូវចាត់គ្រប់វិធានការណ៍សមស្របដើម្បីជួយសំរួលពង្រឹង និង បង្កើនពាណិជ្ជកម្មឱ្យបានច្រើនរូបភាពរវាងប្រទេសទាំងពីរ ។

**<u>មាត្រា ២</u>**

ភាគីចុះហត្ថលេខាត្រូវលើកទឹកចិត្ត និង ផ្តល់នូវការឧបត្ថម្ភជាចាំបាច់ដល់សហគ្រាស និង អង្គភាពដែលពាក់ព័ន្ធ នៃប្រទេសនីមួយៗ ដើម្បីបើកផ្លូវឱ្យមានការរៀបចំខាងវិស័យពាណិជ្ជកម្មក្នុងក្របខ័ណ្ឌ

រយៈពេលខ្លី និង វែង ហើយប្រសិនបើសមស្រប សហគ្រាសនិងអង្គភាពទាំងនោះនឹងចុះកិច្ចសន្យាដោយមានការព្រមព្រៀងទាំងសងខាង ។

## មាត្រា ៣

ភាគីចុះហត្ថលេខានិមួយៗ ត្រូវផ្តល់ឱ្យគ្នាទៅវិញទៅមកនូវ ឋានៈជាប្រជាជាតិអនុគ្រោះបំផុត លើគ្រប់ផ្នែកទាំងអស់ដែលពាក់ព័ន្ធចំពោះពន្ធគយ និង បែបបទពាណិជ្ជកម្មក្រៅប្រទេស ដែលទាក់ទិននឹងការនាំចូល និង.ឬ ការនាំចេញផលិតផល ។

ប្រការនេះមិនត្រូវបានអនុវត្ត ចំពោះអត្ថប្រយោជន៍ សម្បទាន និង ការលើកលែង ដែលភាគីចុះហត្ថលេខាណាមួយបានផ្តល់ ឬ អាចផ្តល់ :

ក. ចំពោះប្រទេសដែលមានព្រំដែនជាប់គ្នា ក្នុងគោលបំណងសំរបសំរួលការធ្វើចរាចរទំនិញតាមព្រំដែន ។

ខ) ចំពោះបណ្តាប្រទេសដែលជាសមាជិកនៃសហភាពគយ ឬ តំបន់ពាណិជ្ជកម្មសេរី ដែលភាគីណាមួយនៃភាគីចុះហត្ថលេខាទាំងពីរ ជា ឬ អាចនឹងក្លាយទៅជាសមាជិក ។

## មាត្រា ៤

ក្នុងគោលបំណងពង្រីកបន្ថែមវិស័យពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ភាគីចុះហត្ថលេខា ត្រូវសំរបសំរួលឱ្យគ្នាទៅវិញទៅមកក្នុងការចូលរួមតាំងពិពណ៌ ដែលនឹងត្រូវប្រារព្ធឡើងក្នុងប្រទេសណាមួយ និង ក្នុងការតាំងបង្ហាញរបស់ប្រទេសណាមួយនៅក្នុងទឹកដីនៃប្រទេសមួយទៀត ក្នុងលក្ខខ័ណ្ឌដែលអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទាំងពីរបានឯកភាពគ្នា ។

ការលើកលែងពន្ធគយ និង អាករផ្សេងទៀត លើសំភារៈ និង ទំនិញគំរូ ដែលយកមកធ្វើការតាំងពិពណ៌ពាណិជ្ជកម្ម និង ការតាំងបង្ហាញ ត្រូវអនុលោមតាមច្បាប់ និង បទបញ្ញត្តិ នៃប្រទេសដែលប្រារព្ធការតាំងពិពណ៌ ឬ ការតាំងបង្ហាញនោះ ។

## មាត្រា ៥

ទំនាស់ទាំងឡាយដែលកើតចេញពីការបកស្រាយ នៃកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមរយៈការទូត ។

## មាត្រា ៦

រាល់ការទូទាត់រវាងប្រទេសទាំងពីរ ត្រូវធ្វើឡើងដោយ រូបិយប័ណ្ណ ដែលអាចផ្ទេរប្តូរបានដោយសេរី ដែលអាចព្រមព្រៀងគ្នាបានរវាងភាគីចុះហត្ថលេខាដោយអនុលោមតាមបទបញ្ញត្តិស្តីអំពីការប្តូរប្រាក់បរទេសជាធរមានក្នុងប្រទេសនិមួយៗ ។

## មាត្រា ៧

យោងតាមតំរូវការចាំបាច់ ប្រការទាំងឡាយនៃកិច្ចព្រមព្រៀងនេះ មិនក៏រឹតសិទ្ធិចំពោះភាគីចុះហត្ថលេខាណាមួយឡើយ ក្នុងការអនុម័ត ឬ ប្រតិបត្តិនូវវិធានការខាងក្រោម :

ក. ចំពោះហេតុផលខាងសុខភាពសាធារណៈ សីលធម៌ សណ្តាប់ធ្នាប់ និង សន្តិសុខ

ខ. ចំពោះការការពាររុក្ខជាតិ និង សត្វ ប្រឆាំងនឹងជំងឺផ្សេងៗ និង ការបំផ្លិចបំផ្លាញនានា

គ. ដើម្បីការពារទ្រព្យសម្បត្តិនៃសិល្បៈរបស់ជាតិ ប្រវត្តិសាស្ត្រ ឬ វត្ថុបុរាណដែលមានតំលៃ ។

## មាត្រា ៨

នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ភាគីមួយណាក៏ដោយ អាចលើកសំណើសុំធ្វើវិសោធន៍កម្មជាលាយល័ក្ខអក្សរ ហើយភាគីម្ខាងទៀតនឹងឆ្លើយតបក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីបានទទួលនូវសំណើនោះ ។

រាល់ការផ្លាស់ប្តូរ និង កែប្រែកិច្ចព្រមព្រៀងនេះ នឹងត្រូវបានធ្វើដោយមិនឱ្យមានការ ខូចប្រយោជន៍

ចំពោះសិទ្ធនិង កាតព្វកិច្ចដែលកើតឡើងពីការអនុវត្តន៍កិច្ចព្រមព្រៀងនេះ មុនកាលបរិច្ឆេទនៃការធ្វើការផ្លាស់ប្តូរ និង កែប្រែឡើយ លុះត្រាតែសិទ្ធិ និង កាតព្វកិច្ចទាំងនោះ ត្រូវបានអនុវត្តយ៉ាង ពេញលេញជាមុនសិន ។

## មាត្រា ៩

កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅពេលដែល ភាគីចុះហត្ថលេខាទាំងពីរបានចុះហត្ថលេខា ហើយនឹងត្រូវមានសុពលភាពរយះពេល ០៥ ( ប្រាំ) ឆ្នាំ ។

បន្ទាប់ពីនោះកិច្ចព្រមព្រៀងនេះនឹងត្រូវបានពន្យាពេលដោយស្វ័យប្រវត្តិសំរាប់រយះពេល០១ ( មួយ) ឆ្នាំម្តងលើកលែងតែ ភាគីចុះហត្ថលេខាណាមួយផ្តល់ដំណឹងជាលាយល័ក្ខអក្សរអំពីគោលបំណងរបស់ខ្លួនក្នុងការបញ្ចប់កិច្ចព្រមព្រៀងនេះរយះពេល០៣( បី )ខែយ៉ាងតិច មុលពេលកិច្ចព្រមព្រៀងនេះអស់សុពលភាព ។

## មាត្រា ១០

មាត្រាទាំងឡាយនៃកិច្ចព្រមព្រៀងនេះត្រូវអនុវត្តបន្ត ទោះបីជាកិច្ចព្រមព្រៀងនេះ ត្រូវបានបញ្ចប់ក៏ដោយ ចំពោះកិច្ចសន្យានានា ដែលបានធ្វើឡើងក្នុងរយះពេលសុពលភាពនៃកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនទាន់បានអនុវត្តចប់សព្វគ្រប់នៅថ្ងៃដែលកិច្ចព្រមព្រៀងនេះផុតសុពលភាព ។

ធ្វើនៅ រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០២ ជា ០២ ( ពីរ) ច្បាប់ដើម ជាភាសាខ្មែរ ហ៊ិនឌី អង់គ្លេស ។ អត្ថបទទាំងអស់មានតំលៃស្មើគ្នា ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសត្រូវបានយកជាគោល ។

| | |
|---|---|
| **ជូសមុខឱ្យរាជរដ្ឋាភិបាល នៃ** | **ជូសមុខឱ្យរដ្ឋាភិបាល នៃ** |
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋឥណ្ឌា** |
| **ចម ប្រសិទ្ធ** | **យ៉ាសវ៉ាន់ ស៊ីនហា** |
| **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** | **រដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស** |